# រឿង ស្រមោចចិត្តធំ



# រឿង ស្រមោចចិត្តធម៌

និពន្ធនិងរៀបរៀងដកស្រង់ពី សៀវភៅគតិលោក ភាគ៤

គូររូបដោយ លោក គឹម សុគន្ធ

រក្សាសិទ្ធិដោយ អង្គការសន្តិស្ម័គ្រចិត្ត(SVA)

បោះពុម្ពឆ្នាំ២០១១

# រឿង ស្រមោចចិត្តធម៌





មានរឿងតំណាលថា រៃជាសត្វដែលចំណាយពេលច្រើន ក្នុងការរាំច្រៀង ពុំខ្វល់ខ្វាយរកស្បៀងអាហារបម្រុងទុកដាក់ សម្រាប់ខ្លួនឡើយ ។



ឯស្រមោច ជាសត្វឧស្សាហ៍ព្យាយាម តែងពាំនាំស្រូវអង្ករ ទុកដាក់ក្នុងលំនៅខ្លួន គិតក្រែងពីការខ្វះខាតទៅថ្ងៃមុខ ។



មានរឿងនិទានថា  ពួករៃមួយក្រុមរស់នៅក្នុងព្រៃដែលមានមេដឹកនាំម្នាក់ ។ មេក្រុមនោះតែងតែនាំក្រុមរបស់ខ្លួន ហើរច្រៀងរាំលេងយ៉ាងសប្បាយ ។





ពួករៃច្រៀងរាំលេងគ្រប់ពេល  មិនថារដូវប្រាំង ឬរដូវវស្សាឡើយ ។ ពេលខ្លះ ពួកវាបាននាំគ្នីគ្នាទៅច្រៀងរាំក្បែរផ្ទះដង្កូវបាក់ខ្នង  ក្នុងពេលដែលពួកដង្កូវកំពុងរកចំណី ។



ជួនកាល ពួកវានាំគ្នាទៅច្រៀងរាំក្បែរពួកឃ្មុំ នៅពេលដែលពួកគេកំពុងក្រេបលំអងផ្កា ។ ពួកវាហិចហើរលេងគ្រប់ទីកន្លែងយ៉ាងសប្បាយ ។



នៅមិនឆ្ងាយពីកន្លែងពួកវែរស់នៅ មានគ្រួសារស្រមោចពីរនាក់ ប្ដីប្រពន្ធ និងកូនបីនាក់ ។ នារដូវប្រាំង ស្រមោចជាប្ដីបាននាំប្រពន្ធ កូនស្វែងរកស្បៀងអាហារយកមកសន្សំទុក បង្ការក្រែងខ្វះខាត នៅរដូវវស្សា ។





ថ្ងៃមួយ ឪពុក និងកូនពៅកំពុងជញ្ជូនគ្រាប់សណ្តែកបាយ ។ ឪពុក នៅខាងមុខខំទាញ ឯកូនពៅជួយរុញពីក្រោយ ។

ដោយឡែក កូនស្រមោចពីរនាក់ទៀតកំពុងសែងគ្រាប់អង្ករ ។ ពួកគេ ធ្វើការស្រុះគ្នាណាស់ មិនចេះមើលបំណាំគ្នាឡើយ ។



បងប្អូនទាំងពីរនាក់ ខំប្រឹងសែងយ៉ាងតតេះតតះ ម្តងទ្រេតទៅឆ្វេង ម្តងទ្រេតទៅស្តាំ ជួនកាលឈប់សម្រាកបន្តិចយកកម្លាំង ហើយសែងតទៅមុខទៀត ។

នៅពីក្រោយអ្នកទាំងពីរ ម្តាយប្រឹងទូលគ្រាប់ពោតទាំងត្រដាបត្រដួស ប៉ុន្តែនៅតែខំ រហូតបានដល់ទីលំនៅ ។



លុះរដូវវស្សាមកដល់ ខ្យល់បក់មកវូៗ យ៉ាងខ្លាំង ភ្លៀងក៏ធ្លាក់ច្រើនមានផ្លេកបន្ទោរភ្លែតៗ រន្ទះផ្ទូងផាំងៗ ។ ពួករៃមិនអាចចេញរកចំណីនិងច្រៀងរាំបានឡើយ ។ ពួកវារត់រកកន្លែងជ្រករៀងៗខ្លួន ។



ពួកវានាំគ្នាសម្ងំនៅក្នុងជម្រក ឱបដៃកំព្រោនៗ សម្លបស្លាប ដោយរងាខ្លាំងពេក ។ ពួកវាកូរពោះគ្រូកៗ ដោយសារគ្មានអាហារ ម្នាក់ៗឃ្លានស្ទើរស្លាប់ទៅហើយ ។



ចំណែក គ្រួសារស្រមោចកំពុងរស់នៅយ៉ាងសុខសាន្ត ព្រមទាំងមានចំណីអាហារបរិភោគទៀតផង ។



ដោយទ្រាំនឹងការស្រេកឃ្លានមិនបាន ពួកវៃក៏នាំគ្នាធ្វើដំណើរទាំង
កណ្ដាលភ្លៀងទៅលំនៅស្ថានរបស់ស្រមោច ដើម្បីសុំខ្ចីស្បៀងអាហារខ្លះ ។



ពេលជួបស្រមោច រៃដោមេក្រុមក៏និយាយថា៖ ឱ សំឡាញ់អើយ! ពួកខ្ញុំមិនមានអ្វីបរិភោគទេ ខ្ញុំមកដើម្បីសុំខ្ចីស្បៀងអាហារយកទៅឱ្យកូនបរិភោគសិន ទម្រាំដល់ខែប្រាំង ខ្ញុំនឹងរកសងសំឡាញ់វិញ ។



ឯស្រមោច កាលបើឮមេក្រុមនិយាយសុំខ្ចីស្បៀង ក៏តបវិញថា៖ អើ សំឡាញ់! ហេតុដូចម្ដេចបានជាកាលពីខែប្រាំង សំឡាញ់ឯងមិនរកអាហារបម្រុងទុក?



មេក្រុមតបថា៖ សំឡាញ់អើយ! ពួកយើងរស់តែសប្បាយនឹងស្រែកច្រៀងរាំលេង ។ ពួកយើងសោកស្ដាយណាស់ ដោយមិនបានរកស្បៀងបម្រុងទុក ។ ខ្ញុំសន្យាថានឹងខំប្រឹងស្វែងរកស្បៀងអាហារសម្រាប់កូនចៅកុំឱ្យខ្វះខាតដូចគ្រានេះទៀត ។



ស្រមោចតបវិញថា៖ អើ! ល្អហើយដែលឯងដឹងពីកំហុសរបស់ខ្លួន ។ ណ្ហើយ! យើងចែកស្បៀងអាហារតិចតួចសម្រាប់កូនចៅឯងចុះ! ។



ស្រមោចឆ្លើយបញ្ជាក់ថា៖ ស្រូវ អង្ករ ពោត សណ្ដែករបស់យើងមានល្មមតែសម្រាប់ប្រពន្ធកូនយើង តែយើងចែករំលែកមួយចំណែកសម្រាប់ពួកឯងចុះ! ។

មេក្រុមក៏ឆ្លើយថា៖ ឱ សំឡាញ់អើយ! ខ្ញុំអរគុណណាស់ដែលសំឡាញ់ចែកស្បៀងអាហារឱ្យពួកខ្ញុំខ្វី ។



កាលបើបានឮស្រមោចពោលដូច្នេះ ពួករៃត្រេកអរណាស់ ហើយក៏លាស្រមោច វិលត្រឡប់ទៅលំនៅស្ថានខ្លួនវិញ ។

អំណើះតមក ទោះបីពួករៃច្រៀងរាំសប្បាយមែនពិត តែពួកគេមិនភ្លេចពីការរកស្បៀងអាហារបម្រុងទុកឡើយ ។ ទន្ទឹមនេះ រៃក៏មិនភ្លេចពីគុណបំណាច់របស់ស្រមោច ដែលជួយពួកគេផងដែរ ។ ពួករៃ និងស្រមោចរាប់អានគ្នាណាស់ ។ រៀងរាល់ពេលទំនេរ ពួកគេតែងនាំគ្នាច្រៀងរាំលេងលំហែកាយយ៉ាងសប្បាយ "ប្រជុំគ្នារីករាយសប្បាយចិត្ត ចូររាំឱ្យ..." ។

...ចប់...



*Move forward, hand in hand.*
Shanti Volunteer Association
*Stand with people in need around the world.*